archive.today
webpage capture
Saved from https://construction-property.com/km/construction-of-two-major-bridges-conn search
no other snapshots from this url
22 Sep 2023 02:30:51 UTC
All snapshots from host construction-property.com
Webpage Screenshot
share download .zip report bug or abuse Buy me a coffee



PH PengHuoth ហ្សបហោស៍ ពេញនិយម ចាប់ពី ជាង12ម៉ឺនដុល្លារ ឡើងទៅ ទិញថ្នាម ចូលនៅថ្នាម...! 016 59 6789
CONTROLLED MODULUS COLUMN +855 98 516 106 |cambodia@menard-asia.com menard



# ការដ្ឋានស្ពានខ្សែកាបធំៗ ២ ខ្សែ នៃគម្រោងអភិវឌ្ឍកោះនរា ជារូមសម្រេចបាន ១៤,៧% ហើយ

១៥ កញ្ញា ២០២១ ព័ត៌មានក្នុងស្រុក 3266 មើល




Johnson Controls គ្រឿងបន្លាស់ម៉ាស៊ីនត្រជាក់ (+855) 60 888 164 / 66 215 888

ការដ្ឋានសាងសង់ស្ពានខ្សែកាបធំៗ ២ ខ្សែ នៅភ្នំពេញ តភ្ជាប់ពីទីក្រុងកោះនរា ទៅផ្លូវជាតិលេខ ១ និងទៅកោះពេជ្រ ជាមធ្យមបានសម្រេចជាង ១៤,៧% ហើយ បើគិតត្រឹមខែកញ្ញា។ នេះបើយោងតាម អ្នកគ្រប់គ្រងគម្រោង លោក ម៉ែន បូលី។

លោកប៉ូលី បានប្រាប់ទស្សនាវដ្ដីសំណង់ និងអចលនទ្រព្យ នៅថ្ងៃទី ១៥ កញ្ញា នេះថា ស្ពានទី ១ ដែលតភ្ជាប់កោះនរាទៅផ្លូវជាតិលេខ១ សម្រេចបានត្រឹម ២,៥% ប៉ុណ្ណោះ ខណៈស្ពានកោះពេជ្រ-កោះនរា សម្រេចបាន ២៧% ហើយ។

គម្រោងទាំង ២ កំពុងអនុវត្តដោយក្រុមហ៊ុន OCIC ដោយបានបើកការដ្ឋាន កាលពីខែតុលា ឆ្នាំ២០២០។ (អានបន្ថែម)

ស្ពានទី១ ជាប្រភេទស្ពានបេតុងយោងកាបដែលមានដែករាងឥន្ទធនូ ២សងខាង តភ្ជាប់ពីផ្លូវជាតិលេខ១ ទៅកាន់តំបន់អភិវឌ្ឍន៍កោះនរា មានបណ្ដោយប្រវែង ៦០ម៉ែត្រ និងទទឹងប្រវែង ២១ម៉ែត្រ។ ស្ពាននេះគ្រោងចំណាយថវិកាចំនួន ១,៦ លានដុល្លារអាមេរិក។

ដោយឡែក ស្ពានទី ២ ជាប្រភេទស្ពានបេតុងខ្សែកាប តភ្ជាប់ពីតំបន់អភិវឌ្ឍន៍កោះនរា ទៅកាន់ទីក្រុងរណបកោះពេជ្រ មានបណ្ដោយប្រវែង ៨២៤ ម៉ែត្រ និងទទឹងប្រវែង ២៤,៥ ម៉ែត្រ និងមានសសរខ្សែកាបកម្ពស់ ៦០ ម៉ែត្រ ចំនួន ២ដើម ដែលមានចម្លាក់ក្បាច់ខ្មែរ។

ស្ពាននេះមានចរាចរទ្វេរទិស ២ទៅ ២មក ហើយគ្រោងចំណាយថវិកាចំនួន ៣៨លានដុល្លារអាមេរិក។

គួរបញ្ជាក់ផងដែរថា គម្រោងស្ពានទាំង ២ នេះ គឺជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍កោះនរាឱ្យទៅជាទីក្រុងរណបថ្មីមួយរបស់ក្រុមហ៊ុន OCIC។ មកដល់ពេលនេះ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃកោះនរាសម្រេចបានជាង ៤៨% ហើយ។ (អានបន្ថែម)

- Video Advertisement -
គ្រឿងខ្មែរស្រកាលេញ Share
Watch on YouTube 0:00 / 0:31
FLOOR COVERING SOLUTIONS BEYOND THE EXPECTED ការពារជម្រាបទឹក ជួសជុលស្នាមប្រេះ ការបិទតំណ

គម្រោងអភិវឌ្ឍន៍

## ព័ត៌មានដែលទាក់ទង

លេខចុងក្រោយ
CONSTRUCTION & PROPERTY
ផ្សព្វផ្សាយពាណិជ្ជកម្ម
Learn How Key Construction Roles Use SYNCHRO To Solve Everyday Challenges
FLOOR COVERING SOLUTIONS BEYOND THE EXPECTED
YORK
CBA EXPO THAILAND INTERNATIONAL CONSTRUCTION, MINING AND BUILDING TECHNOLOGY EXPO 13-15 September 2023 BITEC, Bangkok, Thailand
7ST STEEL 017 333 626 023 990 960




### ចិននឹងសង់រោងចក្រផលិតអាគុយរថយន្តអគ្គិសនីដ៏ធំបំផុត

២១ កញ្ញា ២០២៣

ក្រុមហ៊ុនផលិតអាគុយរបស់ចិន Eve Energy បានចុះហត្ថលេខាលើ MOU ជាមួយ Energy




### រោងចក្រផលិតដែកដ៏ធំមួយ តម្លៃ ៤០លានដុល្លារ នឹងសង់

២១ កញ្ញា ២០២៣

គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះ




### ក្រុមហ៊ុនចិនត្រូវការដីជាង ៣០០ហិកតា ដើម្បីវិនិយោគ

២០ កញ្ញា ២០២៣

ក្រុមហ៊ុនវិនិយោគចិនធំមួយ មកពីខេត្ត អាន ហួយ ត្រូវការដីជាង ៣០០ហិកតា ដើម្បីវិនិយោគផលិតជី




### ចិនព្រមផ្តល់កម្ចីសង់ស្ពានថ្មី១ខ្សែភ្ជាប់តំបន់ចាក់អង្រែ

១៩ កញ្ញា ២០២៣

កម្ពុជា និងចិន បានសម្រេចចុះកិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងសាងសង់ស្ពានទន្លេ




### គម្រោងសង់ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ តម្លៃជាង

១៩ កញ្ញា ២០២៣

គិតត្រឹមថ្ងៃទី១៤ កញ្ញា ២០២៣នេះ គម្រោងសាងសង់ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ (ស្ទឹងបត់-




### ទួរគីបានសិទ្ធិសង់ចំណតយន្តហោះថ្មី១

១៧ កញ្ញា ២០២៣

សាជីវកម្មអាកាសយានដ្ឋានវៀតណាម (ACV) បានជ្រើសរើសក្រុមហ៊ុន Vietur




